# លក្ខណៈរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់គឺមានមួយអង្គ ហើយព្រះអង្គគឺជាព្រះដែលបង្កើតអ្វីៗទាំងអស់។

ព្រះជាម្ចាស់បើកសម្ដែងអង្គទ្រង់ដល់យើងតាមរយៈការបង្កើត ព្រះបន្ទូល និងជីវិតរបស់ពួកហោរារបស់ទ្រង់។

តាមរយៈការបង្កើត យើងឃើញថា ព្រះអង្គមានអំណាច មានភាពច្នៃប្រឌិត និងមានប្រាជ្ញា។

ពួកហោរាបានប្រាប់យើងបន្ថែមទៀតអំពីព្រះជាម្ចាស់ និងផ្លូវរបស់ទ្រង់។ ពួកគាត់បានប្រាប់យើងថា ព្រះជាម្ចាស់ទ្រង់ល្អ! ព្រះអង្គមានព្រះហឫទ័យមេត្តាករុណានិងក្តួលអាណិត គ្រប់ល័ក្ខណ៍និងយុត្តិធម៌ ហើយពេញដោយក្តីស្រឡាញ់និងសប្បុរស។ គ្រប់របស់ល្អក្នុងជីវិតរបស់លោកអ្នក គឺជាអំណោយទានពីព្រះជាម្ចាស់។

**ដោយសារមានព្រះជាម្ចាស់តែមួយអង្គ ហើយព្រះអង្គទ្រង់ល្អ**

**នោះយើងត្រូវតែស្វែងរក ហើយដើរតាមផ្លូវរបស់ទ្រង់។**

# ហោរា អ័ដាម

ដោយសារតែព្រះជាម្ចាស់ពោរពេញដោយសេចក្ដីស្រឡាញ់ និងសេចក្ដីសប្បុរស នោះព្រះអង្គសព្វព្រះហឫទ័យចង់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរបស់ដែលព្រះអង្គបង្កើត ដែលអាចជ្រើសរើសក្នុងការស្រឡាញ់ទ្រង់។ ដូច្នេះហើយ ព្រះអង្គបានបង្កើតលោក អ័ដាម និងនាង អេវ៉ា ហើយប្រទានអំណោយទានក្នុងការជ្រើសរើសដល់ពួកគេ ហើយដាក់ពួកគេនៅក្នុងសួនច្បារមួយ (ស្ថានសួគ៌)។

លោក អ័ដាម និងនាង អេវ៉ា បានជ្រើសរើសមិនស្ដាប់បង្គាប់ទ្រង់ដោយបរិភោគផ្លែឈើដែលព្រះអង្គហាមឃាត់។ ដោយព្រោះតែទង្វើនៃការមិនស្ដាប់បង្គាប់មួយនេះ ពួកគេត្រូវបានជំនុំជម្រះ ផ្ដន្ទាទោស និងបណ្ដេញចេញពីសួនច្បារនោះ។

ព្រះជាម្ចាស់បានបង្កើតមនុស្សមកសម្រាប់នគរស្ថានសួគ៌។ យើងពិតជាមិនសប្បាយរីករាយនៅលើផែនដីនេះនោះទេ ព្រោះផែនដីនេះពោរពេញទៅដោយបញ្ហា និងអំពើអាក្រក់។

**ព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យយើងរស់នៅក្នុងនគរស្ថានសួគ៌ជាមួយនឹងទ្រង់; ប៉ុន្តែ ព្រះអង្គបានជំនុំជម្រះ និងដាក់ទោសដល់លោក អ័ដាម ដូច្នេះហើយ ព្រះអង្គនឹងជំនុំជម្រះ និងដាក់ទោសដល់យើងដែរ។**

# ហោរា ណូអេ

នៅសម័យរបស់ហោរា ណូអេ មនុស្សបានជ្រើសរើសខុសជាបន្តបន្ទាប់។

ការនេះធ្វើឲ្យព្រះជាម្ចាស់មានព្រះហឫទ័យសោកស្ដាយ ហើយខ្ញាល់។ ព្រះអង្គបានជំនុំជម្រះផែនដីទាំងមូល ហើយបានសម្រេចព្រះទ័យបំផ្លាញផែនដីទាំងមូលដោយទឹកជំ- នន់។

ប៉ុន្តែ ហោរា ណូអេ បានស្ដាប់សម្លេងរបស់ព្រះជាម្ចាស់ ហើយបានដើរតាមផ្លូវរបស់ទ្រង់។ ព្រះអង្គបានមានបន្ទូលប្រាប់លោកឱ្យធ្វើទូកដ៏ធំមួយនៅលើដីគោក។ ទោះបើបណ្ដាជនបានសើចចំអកឲ្យលោកក៏ដោយ ក៏លោកនៅតែស្ដាប់បង្គាប់តាមព្រះជាម្ចាស់។ មានតែអ្នកដែលជឿព្រះជាម្ចាស់ ហើយដើរតាមផ្លូវរបស់ទ្រង់ទៅលើទូកនោះប៉ុណ្ណោះទើបបានរួចជីវិត។ អ្នកផ្សេងទៀតបានស្លាប់បាត់បង់ជីវិតនៅក្នុងទឹកជំនន់។

**ទោះបើមនុស្សអាចនឹងសើចចំអកដល់យើងក៏ដោយ ដើម្បីគេចផុតពីការជំនុំជម្រះ នោះយើងត្រូវតែដើរតាមផ្លូវរបស់ព្រះជាម្ចាស់។**

# ហោរា អ័ប្រាហាំ

ហោរា អ័ប្រាហាំ ត្រូវបានគេហៅថា «មិត្តសម្លាញ់របស់ព្រះជាម្ចាស់»។ លោកបានចុះចូលចំពោះព្រះជាម្ចាស់ជាខ្លាំង នៅពេលដែលព្រះអង្គបានសុំលោកឲ្យបូជាកូនរបស់លោក នោះលោកសុខចិត្តធ្វើតាមទ្រង់។

ប៉ុន្តែ នៅពេលដែលលោក អ័ប្រាហាំ ហៀបនឹងយកកាំបិតចាក់កូនរបស់លោក នោះព្រះជាម្ចាស់បានចាត់កូនចៀមមួយក្បាលមកជំនួសវិញ ហើយ«បានលោះកូនរបស់លោកដោយយញ្ញបូជាដ៏អស្ចារ្យមួយយ៉ាងធំ» ។ នេះជាអ្វីដែលគេប្រារព្ធនៅ «ថ្ងៃបុណ្យនៃការធ្វើយញ្ញបូជា» ( Eid al Adha)។

**ទោះបើព្រះជាម្ចាស់អាចនឹងទាមទារយញ្ញបូជាក៏ដោយ**

**ក៏ព្រះអង្គនឹងផ្តល់យញ្ញបូជាជំនួសផងដែរ។**

# ហោរា ម៉ូសេ

ព្រះជាម្ចាស់បានប្រទានដល់ហោរា ម៉ូសេ នូវក្រឹត្យវិន័យដប់ប្រការ និងច្បាប់ជាច្រើនទៀតសម្រាប់ជនជាតិយូដា។ ព្រះអង្គបានសន្យាថា នឹងប្រទានពរដល់ជនជាតិយូដា ប្រសិនបើពួកគេគោរពតាមក្រឹត្យវិន័យទាំងនោះ។ កិច្ចព្រមព្រៀងនេះត្រូវបានគេហៅថា សេចក្ដីសញ្ញាចាស់។ ប៉ុន្តែ ក្រឹត្យវិន័យទាំងនោះមានភាពស្មុគស្មាញណាស់ ដែលធ្វើឲ្យពួកគេមិនអាចកាន់តាមបានល្អឥតខ្ចោះនោះទេ។

ពួកយូដាបានដឹងថា ដោយសារតែភាពយុត្តិធម៌របស់ព្រះជាម្ចាស់ នោះពួកគេនឹងត្រូវជំនុំជម្រះ ដូចលោក អ័ដាម បានទទួលការជំនុំជម្រះផងដែរ។ ក៏ប៉ុន្តែ ដូចជាលោក អ័ប្រាហាំ និងកូនប្រុសរបស់លោកដែរ ព្រះជាម្ចាស់បានបង្កើតផ្លូវមួយសម្រាប់ពួកគេ។

**សេចក្ដីសញ្ញាចាស់រួមបញ្ចូលយញ្ញបូជាឈាមសម្រាប់អំពើបាប។**
**យញ្ញបូជាទាំងនោះបង្ហាញថា អំពើបាបគឺសមនឹងសេចក្ដីស្លាប់។**

# សេចក្តីសញ្ញាចាស់បានបញ្ចប់

ហោរា ម៉ូសេ បានព្រមានដល់សាសន៍យូដាថា ពួកគេមិនត្រូវចាកចេញពីព្រះជាម្ចាស់ទៅតាមព្រះដទៃទៀយ។ ការធ្វើដូច្នេះនឹងធ្វើឲ្យសេចក្តីសញ្ញារបស់ពួកគេបានបញ្ចប់។ ពួកគេនឹងទទួលការវាយប្រហារ ហើយបញ្ជូនទៅធ្វើជាទាសករទៅប្រទេសផ្សេង។ ជាច្រើនឆ្នាំក្រោយមក ពួកយូដាបានងាកទៅថ្វាយបង្គំរូបព្រះ ហើយការព្រមាននេះត្រូវបានអនុវត្ត។

កាលពួកយូដាជាប់ជាឈ្លើយនៅស្រុក បាប៊ីឡូន ព្រះជាម្ចាស់បានចាត់ហោរាផ្សេងទៀតឲ្យមកឯពួកគេជាមួយនឹងសេចក្តីទំនាយដែលពេញដោយសេចក្តីសង្ឃឹម។ ពួកគេបាននិយាយអំពីសេចក្តីសញ្ញាថ្មី ដែលនឹងមានសម្រាប់មនុស្សទាំងអស់។

**នឹងមានសេចក្តីសញ្ញាថ្មីមួយជាមួយនឹងយញ្ញបូជាចុងក្រោយ គឺ «កូនចៀមនៃព្រះ» ។**

# ពួកហោរាបានសន្យាពីព្រះសង្គ្រោះមួយអង្គ

ហេតុអ្វីបានជាហោរា យេស៊ូវ ខុសប្លែកពីហោរាដទៃទៀតទាំងអស់? ហេតុអ្វីបានជាហោរានេះតែមួយគត់ដែលគេហៅថា ព្រះបន្ទូលនៃព្រះ ហើយអ្នកខ្លះទៀតហៅថា ព្រះវិញ្ញាណនៃព្រះ? ហេតុអ្វីបានជាហោរាម្នាក់នេះដែលបានប្រសូតនឹងស្ត្រីព្រហ្មចារី ហើយគ្មានបាបសោះ នឹងត្រូវជំនុំជម្រះពិភពលោកទាំងមូល?

សត្វសម្រាប់ធ្វើយញ្ញបូជាត្រូវតែល្អឥតខ្ចោះ។ ព្រះយេស៊ូវគឺជាយញ្ញបូជាដ៏បរិសុទ្ធចុងក្រោយបង្អស់ដែលជា «កូនចៀមនៃព្រះ» ។ ហោរា អេសាយ បានទាយទុកជាមុនថា យញ្ញបូជាចុងក្រោយនេះ គឺជាព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់។ ព្រះអង្គនឹងប្រសូតមកលើផែនដីនេះ ហើយត្រូវបានគេហៅថា «ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព»។

# ព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានរក្សា

ហោរា អេសាយ ក៏បានទាយទុកជាមុនថា វាជាព្រះហឫទ័យរបស់ព្រះអម្ចាស់ដែលព្រះមែស្ស៊ី ធ្វើជាតង្វាយសម្រាប់ការរំលង រាប់ជាសុចរិត និងទទួលយកអំពើទុច្ចរិតរបស់ពួកគេ។

គ្រីស្ទបរិស័ទមិនបានបង្កើតពាក្យទាំងនេះឡើង ឬបន្ថែមពាក្យទាំងនេះទៅក្នុងព្រះគម្ពីរនោះទេ។ ពាក្យទំនាយទាំងនេះត្រូវបានសរសេរ ៦០០ ឆ្នាំមុនព្រះយេស៊ូវប្រសូត ហើយត្រូវបានរក្សាទុកនៅក្នុងក្រាំងសមុទ្រស្លាប់។ ក្រាំងគម្ពីរទាំងនោះត្រូវបានរក្សាទុកនៅក្នុងរូងភ្នំក្នុងស្រុក ប៉ាឡេស្ទីន មុនពេលដែលព្រះយេស៊ូវប្រសូត រហូតដល់ត្រូវបានគេរកឃើញឡើងវិញនៅសតវត្សរ៍ទី ២០។

**ព្រះជាម្ចាស់រក្សាព្រះបន្ទូលរបស់ទ្រង់!**

# ហេតុអ្វីត្រូវធ្វើយញ្ញបូជាឈាម ?

ការយល់ដឹងពីលក្ខណៈរបស់ព្រះជាម្ចាស់ ពន្យល់បន្ថែមអំពីសកម្មភាព និងផ្លូវរបស់ទ្រង់។ លក្ខណៈសម្បត្តិរបស់ទ្រង់គឺមានតុល្យភាព។

*ភាពយុត្តិធម៌របស់ទ្រង់ស្មើនឹងសេចក្តីមេត្តាករុណារបស់ទ្រង់ពេញដោយកម្លាំង។*

សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ជំរុញព្រះអង្គឱ្យស្វែងរកវិធីដើម្បីអត់ទោសឱ្យយើង ហើយធ្វើឱ្យយើងមានទំនាក់ទំនងជាមួយនឹងទ្រង់ឡើងវិញ។ សេចក្តីមេត្តាករុណារបស់ទ្រង់គឺអស្ចារ្យណាស់ ប៉ុន្តែមិនអាចយកឈ្នះលើភាពយុត្តិធម៌របស់ទ្រង់បានទេ។ ព្រះអង្គមិនអាចគ្រាន់តែអត់ទោសឲ្យ ហើយបំភ្លេចចោលនោះឡើយ។ ចរិតលក្ខណៈរបស់ព្រះជាម្ចាស់ទាមទារយុត្តិធម៌៖ សេចក្តីស្លាប់សម្រាប់អំពើបាប។

*តើព្រះអង្គអាចមានព្រះហឫទ័យមេត្តាករុណា និងយុត្តិធម៌ក្នុងពេលតែមួយដោយរបៀបណា ?* ដោយផ្តល់នូវយញ្ញបូជាជំនួស។ តើអ្វីជាភស្តុតាង ? ព្រះអង្គបានបង្ហាញផ្លូវនេះដល់យើងជាមួយនឹងហោរារបស់ទ្រង់ ដូចជា លោក អ័ដាម លោក ណូអេ លោក អ័ប្រាហាំ លោក ម៉ូសេ និងពួកយូដា ឲ្យធ្វើយញ្ញបូជាឈាម។ ក្រៅពីសត្វមួយគូៗ ហោរា ណូអេ បានយកសត្វចំនួនប្រាំពីរប្រភេទសម្រាប់ថ្វាយយញ្ញបូជាដាក់លើទូកធំ ហើយធ្វើយញ្ញបូជានៅពេលគាត់ចុះពីទូក។

ហោរា យ៉ាហ៊ីយ៉ា (លោកយ៉ូហានបាទីស្ទ) បានទទួលស្គាល់ព្រះយេស៊ូវថាជាយញ្ញបូជាចុងក្រោយ គឺជា «កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក»។

# ហេតុអ្វីបានជាព្រះជាម្ចាស់...

យកនិស្ស័យជាមនុស្ស ហើយសុគតទុកជាយញ្ញបូជា? គឺដោយសារតែលក្ខណៈរបស់ព្រះជាម្ចាស់ ។ មានតែព្រះជាម្ចាស់ទេដែលល្អឥតខ្ចោះ។ ភាពល្អឥតខ្ចោះរបស់ទ្រង់គឺទាមទារ ឱ្យយើងល្អឥតខ្ចោះផងដែរ។ ព្រះជាម្ចាស់សប្បាយព្រះទ័យ ប្រសិនបើយើងល្អឥតខ្ចោះ; ប៉ុន្តែយើងនឹងមិនដែលល្អឥតខ្ចោះនោះទេ។ ប្រៀបដូចជាកូនក្មេងដែលឲ្យប្រាក់ប្រាំសេនដល់ឪពុកដើម្បីបង់ថ្លៃជួសជុលបង្អួចដែលខូចអញ្ចឹង ឪពុកពិតជាកោតសរសើរនូវអ្វីដែលកូននោះបានធ្វើ ប៉ុន្តែគាត់ដឹងថា ខ្លួនគាត់នឹងត្រូវបង់ថ្លៃជួសជុល ដ្បិតគាត់ជាអ្នកទទួលខុសត្រូវ។

ភាពល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ក៏ទាមទារឱ្យព្រះអង្គជួសជុលពិភពលោកដ៏អាក្រក់នេះនៅកណ្តាលចក្រវាឡដ៏ស្រស់ស្អាតរបស់ទ្រង់។ ការសុគតរបស់ព្រះយេស៊ូវ គឺជាផ្លូវដែលព្រះជាម្ចាស់បានកំណត់ទុក និងទទួលខុសត្រូវចំពោះការរងទុក្ខលំបាកទាំងអស់នៃពិភពលោក។ ព្រះជាម្ចាស់យល់ពីរបៀបដែលយើងរងទុក្ខលំបាក ដ្បិត

**ព្រះបន្ទូលរបស់ទ្រង់បានត្រឡប់ជាសាច់ឈាម ហើយរស់នៅជាមួយនឹងយើង។**

# របៀបចូលទៅឯនគរស្ថានសួគ៌

ប្រសិនបើយើងគិតថា យើងអាចសង្គ្រោះខ្លួនឯងបានដោយអំពើល្អរបស់យើងផ្ទាល់ នោះយើងដណ្ដើមយកសិរីល្អរបស់ព្រះជាម្ចាស់ ហើយតាំងខ្លួនជាដៃគូជាមួយនឹងទ្រង់ក្នុងសេចក្ដីសង្គ្រោះរបស់យើងហើយ។

គ្មានអ្នកណាទៅនគរស្ថានសួគ៌បានក្រៅពីសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់នោះទេ។ ព្រះជាម្ចាស់បានបង្ហាញយើងឲ្យឃើញតាមរយៈហោរារបស់ទ្រង់ថា ផ្លូវរបស់ទ្រង់គឺជាយញ្ញបូជា ប៉ុន្តែព្រះអង្គផ្ដល់នូវយញ្ញបូជាជំនួស។ ក្នុងភាពយុត្តិធម៌ និងសេចក្ដីមេត្តាករុណា ព្រះជាម្ចាស់បានបង្កើតផ្លូវមួយដើម្បីនាំយើងត្រឡប់ទៅនគរស្ថានសួគ៌វិញ។ ព្រះអង្គបានយាងមកផែនដីម្ដង ជាយញ្ញបូជាដ៏ល្អឥតខ្ចោះចុងក្រោយបង្អស់ ដែលពួកហោរាបានទាយទុកជាមុន គឺព្រះយេស៊ូវគ្រីស្ទ។

យើងទាំងអស់គ្នានឹងទទួលការជំនុំជម្រះ។ តើលោក អ័ប្រាហាំ និងកូនប្រុសរបស់លោកទទួលបានសេចក្ដីមេត្តាករុណាពីព្រះជាម្ចាស់យ៉ាងដូចម្ដេច? គឺតាមរយៈកូនចៀមដែលព្រះបានប្រទាន។ តើនឹងមានអ្វីកើតឡើង ប្រសិនបើពួកគេមិនទទួលយកកូនចៀមនោះទេ? កូនប្រុសរបស់លោកនឹងស្លាប់។ តើនឹងមានអ្វីកើតឡើងចំពោះយើង ប្រសិនបើយើងមិនទទួលយកការប្រទានឲ្យរបស់ព្រះជាម្ចាស់នោះទេ? នោះយើងក៏នឹងស្លាប់ផង ដែរ។

# យើងត្រូវទទួលយកផ្លូវរបស់ព្រះជាម្ចាស់!

ដើម្បីទទួលយកផ្លូវនៃសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ ត្រូវសារភាពអំពើបាបរបស់លោកអ្នក ហើយជឿថា ព្រះជាម្ចាស់បានទទួលជំនួសលោកអ្នកតាមរយៈព្រះយេស៊ូវ។

បន្ទាប់មក ជីវិតថ្មីរបស់លោកអ្នកជាមួយនឹងព្រះជាម្ចាស់ចាប់ផ្តើមដោយៈ អធិស្ឋាន ហើយអានព្រះគម្ពីរជារៀងរាល់ថ្ងៃ
ប្រកបជាមួយអ្នកដទៃដែលជឿថាព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ ស្រឡាញ់មនុស្សគ្រប់គ្នា ហើយចែកចាយដំណឹងល្អនៃការអត់ទោសតាមរយៈទ្រង់!

ឯកសារយោងៈ ព្រះគម្ពីរ (Taurat, Zabur, Injil)ៈរ៉ូម ៣:២១-២៦, ទំនុកតម្កើង ១១៨:១, លោកុប្បត្តិ ៣:៦-៨,២២, គម្ពីរកូរ៉ាន ៣៧:១០៧, ព្រះគម្ពីរៈ និក្ខមនំ ២០, ២៤, ចោទិយកថា ២៩, យេរេមា ៣១:៣១, យ៉ូហាន ១:១,១៤ & ៥:២៧, អេសាយ ៩:៦,៧ & ៤០:៨ & ៥៣:១០-១២, រ៉ូម ១០:៩,១០, ហេព្រើរ ២:១០, ៤:១៦, ១០:២៥, យ៉ូហាន ១៥, ម៉ាថាយ ២៨:១៨-២០។

រៀបចំដោយគម្រោង Palm របស់អង្គការ AEM

ព័ត៌មានបន្ថែមៈ www.ChristianFromMuslim.com

( 866 ) 533-6659